អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន
## ការតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងថ្មីនៅ អ.វ.ត.ក

បន្ទាប់ពីមានការស្នើតែងតាំងពីឯកឧត្តម António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណា សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ទ្រង់បានតែងតាំងលោក Fergal GAYNOR (ជនជាតិអៀរឡង់) ជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងថ្មី។

លោក Gaynor បានបំពេញការងារជាមេធាវីជំនុំជម្រះ (Trial Attorney) ក្នុងការិយាល័យរដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៣ មុនពេលបំពេញការងារជាជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញានៅ អ.វ.ត.ក ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦។ គាត់ធ្លាប់បំពេញការងារជាមេធាវីនាំមុខតំណាងជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក្នុងសំណុំរឿងប្រឆាំងនឹងប្រធានាធិបតីកេនយ៉ា Uhuru Kenyatta ចាប់ពីឆ្នាំ២០១២ មក និងជាតំណាងជនរងគ្រោះមួយក្រុមនៅក្នុងស្ថានភាពនៅប្រទេសអាហ្វហ្កានីស្ថាន ចាប់ពីឆ្នាំ២០១៩ មក ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងការស៊ើបអង្កេតនៅតុលាការ ICC។

លោក Gaynor ទទួលបានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រពីមហាវិទ្យាល័យ Trinity College Dublin និងសញ្ញាបត្រអនុបណ្ឌិតទស្សនវិជ្ជាពីសាកលវិទ្យាល័យ Cambridge។ គាត់ជាសមាជិកគណៈមេធាវីអៀរឡង់ និងជាសមាជិកគណៈកម្មាធិការនិពន្ធនាយកនៃព្រឹត្តិប័ត្រ Journal of International Criminal Justice។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត៖ +៨៥៥(0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ៖ +៨៥៥(0)២៣ ៨៦១ ៥៦៤
អ៊ីមែល៖ neth.pheaktra@eccc.gov.kh